សម្លេងខ្មែរនៅបរទេស

# ការវិភាគ

## របស់ព្រះតេជព្រះគុណបណ្ឌិត ហុក-សាវណ្ណ
## ក្រោមប្រធានបទ ព្រហ្មវិហារធម៌

www.hoksavann.org

ថ្ងៃទី២ មិថុនា ២០១៣



«**ព្រហ្មវិហារធម៌**» ប្រែថា ធម៌ជាទីនៅដ៏ប្រសើរ បានដល់គុណធម៌នៃចិត្តរបស់មនុស្ស ដែលមានចំពោះមនុស្សសត្វទូទៅ ។ **ព្រហ្មវិហារធម៌** មាន២ប្រការគឺ ព្រហ្មវិហារធម៌របស់មាតាបិតា ដែលរាប់អានស្រឡាញ់អាណិតសង្គ្រោះចំពោះបុត្រធីតាប្រុសស្រី ។ ព្រហ្មវិហារធម៌មួយទៀតគឺ **អប្បមញ្ញាព្រហ្មវិហារ** ប្រែថា ព្រហ្មវិហារកំណត់ចំនួនមិនបាន បានដល់ការផ្សាយ **មេត្តា ករុណា មុទិតា** និង**ឧបេក្ខា** ដល់សព្វសត្វទូទៅកំណត់ចំនួនមិនបាន គឺជាព្រហ្មវិហារនៃលោកអ្នកដែលមានចិត្តទូលាយ ជាពិសេសផ្នែកលោកអ្នក ចំរើនឈានចិត្ត ដែលយក **មេត្តា ករុណា មុទិតា ឧបេក្ខា** ជាអារម្មណ៍ ដែលមានលក្ខណៈ ផ្សេងគ្នាពីព្រហម្មវិហារធម៌របស់មាតាបិតា ដែលមានចំពោះតែកូនរបស់គាត់តែប៉ុណ្ណោះ ។

ព្រហ្មវិហារធម៌របស់មាតាបិតាចំពោះបុត្រធីតា គឺ**មេត្តា** មានចិត្តរាប់អានកូនតាំងពីតូចមក ចាប់បដិសន្ធិក្នុងផ្ទៃរបស់ខ្លួនម្ល៉េះ គឺចង់ឃើញកូនមានរាងរៅបែបណា លុះកើតមកហើយ ក៏មានចិត្តរីករាយចាប់បំបៅដោះបំរើកូនដូចបាវបំរើ ។ **ករុណា** ប្រែថា អាណិតអាសូរ គឺពេលកូនមានទុក្ខដូចជាកូនមានជម្ងឺ ក៏មានចិត្តអាណិតអាសូរកូន យកកូនទៅមន្ទីរពេទ្យដើម្បីព្យាបាលជាដើម ។ **មុទិតា** ប្រែថា មានចិត្តរីករាយ គឺពេលដែលកូនបានសេចក្តីសុខពុំមានជម្ងឺ មានសុខភាពល្អជាដើម មាតាបិតាក៏មានចិត្តសប្បាយរីករាយ ។ **ឧបេក្ខា** ប្រែថា ចិត្តស្ថិតនៅជាកណ្តាល មិនបារម្ភខ្វល់ខ្វាយដូចមុន ។

**ព្រហ្មវិហារធម៌** ដែលមានចិត្តទូលំទូលាយ ផ្សាយទៅចំពោះសព្វសត្វទាំងអស់ ។ **មេត្តា** ប្រែថា ការរាប់អាន គឺរាប់អានចំពោះមនុស្សសត្វទូទៅមិនរើសមុខ ។ មេត្តានេះមានមនុស្សសត្វជាអារម្មណ៍ ។ លើសពីនេះទៅទៀត មេត្តានេះពុំមែនរាប់អានតែមនុស្សជាតិប៉ុណ្ណោះទេ គឺស្រឡាញ់រាប់អានរហូតដល់សត្វតិរច្ឆានផងទៀត ។ ការបណ្តុះចិត្តឲ្យមានមេត្តា គឺដើម្បីដោះចិត្តចេញពីមានះ ការប្រកាន់ជាតិត្រកូល ទ្រព្យសម្បត្តិ យសស័ក្តិជាដើម ។ **ករុណា** ប្រែថា ការអាណិតអាសូរ គឺមានចិត្តអាណិតអាសូរចំពោះមនុស្សសត្វដែលមានទុក្ខ ដូចជាមានជម្ងឺតម្កាត់បៀតបៀន ក្រខ្សត់ អត់ឃ្លាន មានទុក្ខវេទនាដោយហេតុអ្វីមួយ ក៏កើតមានចិត្តអាណិតអាសូរ ហើយទៅជួយសង្គ្រោះ ។ **ករុណា** មានសេចក្តីទុក្ខរបស់មនុស្សសត្វជាអារម្មណ៍ ។ ការបង្កើតចិត្តឲ្យមានករុណា គឺដើម្បីកំចាត់បង់នូវការព្យាបាទ ការបៀតបៀនអ្នកដទៃ ។ ការកើតចិត្តអាណិតអាសូរបែបនេះ ដោយពិចារណាថា មនុស្សសត្វទាំងអស់តែងមានទុក្ខ ម្តងគេមានទុក្ខ ម្តងយើងមានទុក្ខ ដូច្នេះមិនត្រូវបៀតបៀនគ្នាទេ ត្រូវតែជួយសង្គ្រោះគ្នាវិញ ។ **មុទិតា** ប្រែថា ត្រេកអរ គឺមានចិត្តត្រេកអរចំពោះសេចក្តីសុខអ្នកដទៃ ។ បានសេចក្តីថា បើអ្នកដទៃមានសុខភាពល្អ ហើយមានទ្រព្យសម្បត្តិល្មមនឹងចិញ្ចឹមជីវិតបានហើយ មានសិទ្ធិសេរីភាពហើយ ក៏ជួយអនុមោទនាត្រេកអរ ។ **មុទិតា** នេះមានទ្រព្យសម្បត្តិនិងសេចក្តីសុខរបស់អ្នកដទៃជាអារម្មណ៍ ។ គោលបំណងនៃការផ្សាយមុទិតាចិត្ត គឺជៀសវាងការប្រណែនគ្នា ។ បើគេមានបានដោយរកស៊ីត្រឹមត្រូវក្នុងក្របខណ្ឌនៃច្បាប់រដ្ឋ រៀនសូត្រចេះដឹងច្រើន អ្នកដទៃត្រូវជួយត្រេកអរ ។ ចំណែកអ្នកមានបានអ្នកមានចំណេះខ្ពស់ គួរជួយអ្នកក្រខ្សត់អត់ឃ្លាន អ្នកមានចំណេះទន់ខ្សោយជាងខ្លួន ។ **ឧបេក្ខា** ប្រែថា ចិត្តនៅកណ្តាល ព្រោះសេចក្តីទុក្ខខ្លះដូចជាមនុស្សស្លាប់ គេពុំអាចឲ្យរស់ឡើងវិញបានឡើយ ។ បើប្រើករុណាចិត្តអាណិតអាសូរចំពោះជនជាទីស្រឡាញ់ ដែលស្លាប់បាត់បង់ជីវិតទៅហើយនោះ គេរមែងកើតទុក្ខខ្លាំងណាស់ ។ ខ្លះកើតទុក្ខខ្លាំងរហូតធ្វើអត្តឃាតខ្លួនឯងក៏មាន ។ ដូច្នេះ **ឧបេក្ខា** នេះត្រូវពិចារណាកម្មផលរបស់មនុស្សសត្វ មានកម្មផលរបស់មនុស្សសត្វជាអារម្មណ៍ ប្រើចិត្តឧបេក្ខាដើម្បីកុំឲ្យខូចផ្លូវចិត្ត ។

ដូចបានពោលមកហើយ បើមនុស្សនិងសង្គមមនុស្សប្រតិបត្តិតាមព្រហ្មវិហារធម៌ទាំង៤ប្រការនេះ ពិតជាធ្វើឲ្យពិភពលោក ជាពិសេសសង្គមខ្មែរបានសុខសន្តិភាព ព្រោះព្រហ្មវិហារធម៌នេះជាទឹកបន្សារ សំរាប់ផ្សារភ្ជាប់រវាងមនុស្សនិងមនុស្ស សង្គមមនុស្សនិងសង្គមមនុស្សឲ្យរត់រកគ្នា និងរស់នៅជាមួយគ្នាប្រកបដោយសេចក្តីសុខសាន្ត ហើយសង្គ្រាមគ្រប់ប្រភេទរមែងពុំកើតមានឡើយ ។

តាមអ្នកស្រាវជ្រាវប្រវត្តិសាស្ត្រខ្មែរយល់ឃើញថា សម័យព្រះបាទជ័យវរ្ម័នទី៧ ដែលធ្វើឲ្យរាជាណាចក្រកម្ពុជាអាចបង្រួបបង្រួមជាតិបាន ដោយព្រះអង្គអនុវត្តតាមព្រហ្មវិហារធម៌ មេត្តា ករុណា មុទិតា និងឧបេក្ខា ។ ព្រះអង្គជាព្រះពោធិសត្វក្នុងពុទ្ធសាសនាមហាយានផង ជាស្តេចផែនដីផង ដូចនេះ បញ្ញារបស់ព្រះអង្គជាបញ្ញារបស់ព្រះពោធិសត្វ ។ សម័យរបស់ព្រះអង្គមានទឹកដីធំទូលំទូលាយ មានអរិយធម៌ខ្ពង់ខ្ពស់ ហើយបានជះឥទ្ធិពលរបស់ខ្លួនទៅលើប្រទេសជិតខាងទៀតផង ។ ចំពោះព្រះពុទ្ធ ព្រះអង្គសំដែងព្រហ្មវិហារធម៌ផង អនុវត្តតាមធម៌នេះផង ដោយព្រះអង្គសំដែងធម៌ប្រោសសត្វ ព្រោះមានព្រះទ័យករុណាអាណិតអាសូរដល់សត្វ ដែលកំពុងស្លាប់កើតក្នុងវដ្តសង្សារ ។ ពេលដែលភិក្ខុទេវទត្ត និងព្រះបាទសុប្បពុទ្ធតាមព្យាបាទ ព្រះអង្គតែងផ្សាយមេត្តានិងករុណាដល់ជនទាំងនោះ ដោយពុំតបតដោយអកុសលចិត្តណាមួយឡើយ ។ ចំពោះរឿងនេះ មិនចំពោះតែព្រះពុទ្ធទេ សូម្បីសាសនាដទៃទៀត ដូចសាសនាព្រះយេស៊ូ ពេលដែលគេចាប់ព្រះអង្គឆ្កាង ព្រះអង្គសុខចិត្តទទួល ពុំតបនឹងជនទាំងនោះឡើយ ។៚

❑